00455113

**Declassified to Public**
**12 April 2013**

D274/4/1

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 12 / 02 / 2010
ម៉ោង (Time/Heure): 15:20
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**ចំពោះមុខអង្គបុរេជំនុំជម្រះ**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ : ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៤៧) | ភាគីដាក់ឯកសារ : សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

ដាក់ជូន: អង្គបុរេជំនុំជម្រះ | ភាសាដើម : អង់គ្លេស

កាលបរិច្ឆេទឯកសារ: ១២ កុម្ភៈ ២០១០

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ : សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះ : សម្ងាត់ / Confidential / Confidentiel

ស្ថានភាពនៃចំណាត់ថ្នាក់ឯកសារ:

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរួមលើសំណើសុំបំពេញកិច្ចស៊ើបសួរពីររបស់សហព្រះរាជអាជ្ញាទាក់ទិននឹងខ្មែរក្រោម និងសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំឲ្យធ្វើការស៊ើបអង្កេតបន្ថែមទាក់ទិននឹងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ចំពោះខ្មែរកម្ពុជាក្រោម និងជនជាតិវៀតណាម**

---

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 16 / 02 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ដាក់ដោយ :

សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី:

នី ចាន់នី
Mahdev MOHAN
Lyma NGUYEN

ចូលរួមដោយ :
Silke STUDZINSKY

ជំនួយការផ្នែកច្បាប់:

សាស្ត្រាចារ្យ Laurel E. FLETCHER
Jeffrey BAE
Levon KEVORKIAN
Sari AZIZ

ផ្ញើជូន :

អង្គបុរេជំនុំជម្រះ :

ចៅក្រម ប្រាក់ គឹមសាន
ចៅក្រម ន័យ ថុល
ចៅក្រម ហួត វុទ្ធី
ចៅក្រម Katinka LAHUIS
ចៅក្រម Rowan DOWNING

សហមេធាវីសម្រាប់ជនត្រូវចោទ :

អៀង សារី
អាង ឧត្តម
Michael G. KARNAVAS

អៀង ធីរិទ្ធ
ផាត់ ពៅ ស៊ាង
Diana ELLIS

នួន ជា
សុន អារុណ
Michel PESTMAN
Victor KOPPE

ខៀវ សំផន
ស ស្វាន
Jacques VERGES

**កាំង ហ្គេកអ៊ាវ ហៅឌុច**

ការ សាវុត្ថ

François ROUX.
Marie-Paule CANIZARES

**សហព្រះរាជអាជ្ញា**

ជា លាង

Andrew T. CAYLEY

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ហុង គឹមសួន

ឡោ ជុនធី

គឹម ម៉េងឃី

គង់ ពិសី

យ៉ុង ផានិត

ស៊ីន សុវ៉ាន

ម៉ុច សុវណ្ណារី

Martine JACQUIN
Philippe CANONNE
Elizabeth RABESANDRATANA
Annie DELAHAIE
Olivier BAHOUGNE
Patrick BAUDOIN
Fabienne TRUSSES-NAPROUS
David BLACKMAN
Patrick BAUDOIN
Marie GUIRAUD

**ដើមបណ្តឹងរដ្ឋប្បវេណីគ្មានមេធាវីតំណាង**

## I. សេចក្ដីផ្ដើម និងញត្តិ

យោងទៅតាមវិធាន៥៥(១០) វិធាន៧៤(៤)(ក)និងវិធាន៧៥នៃវិធានផ្ទៃក្នុងនៃអ.វ.ត.ក សហមេធាវីសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណីដែលជាខ្មែរក្រោមទាំង៩នាក់[1] និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដែលជាខ្មែរក្រោម១៧នាក់[2] និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដែលជាជនជាតិភាគតិចវៀតណាម១៦នាក់ ("ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី"ជាបណ្ដុំ)[3] សូមដាក់បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេត (OCIJ) លើសំណើចំនួនពីររបស់សហព្រះរាជអាជ្ញាសម្រាប់ការស៊ើបអង្កេតពាក់ព័ន្ធនឹងខ្មែរកម្ពុជាក្រោម និងការសម្លាប់រង្គាលទ្រង់ទ្រាយធំនៅស្រុកបាកាន (ខេត្តពោធិ៍សាត់) និងសំណើរបស់ដើមបណ្ដឹងរដ្ឋប្បវេណីស្នើសុំឱ្យមានការស៊ើបអង្កេតបន្ថែមពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រល័យពូជ

---

[11] **KK01** Civil Party 09-VU-02140 (accepted as a Civil Party on 14 January 2010, ); **KK02** Civil Party 09-VU-02139 (accepted as a Civil Party on 14 January 2010); **KK04** Civil Party 09-VU-02137 (accepted as a Civil Party on 14 January 2010); **KK06** Civil Party 09-VU-02135 (accepted as a Civil Party on 14 January 2010); **KK07** Civil Party 09-VU-02134 (accepted as a Civil Party on 14 January 2010); **KK08** Civil Party 09-VU-02133 [08-VU-02103] (accepted as a Civil Party 14 January 2010); **KK25** Civil Party 08-VU-02131 (accepted as a Civil Party 14 January 2010, D22/0132); **KK12** Civil Party 09-VU-02149 [08-VU-01574] (accepted as a Civil Party on 14 January 2010); **KK27** Civil Party 09-VU-04266 (accepted as a Civil Party on 14 January 2010)។

[2] **KK03** Civil Party application 09-VU-02138, D22/0260; **KK05** Civil Party application 09-VU-02136, D22/0260; **KK10** Civil Party application 09-VU-02151, D22/0273; **KK11** Civil Party application 09-VU-02150; **KK13** Civil Party application 09-VU-02148, D22/0270; **KK14** Civil Party application 09-VU-02147, D22/0269; **KK15** Civil Party application 09-VU-02145, D22/0267; **KK16** Civil Party application 09-VU-02146, D22/0268; **KK17** Civil Party application 09-VU-02144, D22/0268; **KK18** Civil Party application 09-VU-02143, D22/0265; **KK19** Civil Party application 09-VU-02142, D22/0264; **KK 20** Civil Party application 09-VU-02141, D22/0263; **KK21** Civil Party application 09-VU-00638, D22/0134; **KK22** Civil Party application 09-VU-02267, D22/0135; **KK23** Civil Party application 09-VU-00641, D22/0101; **KK24** Civil Party application 09-VU-02130, D22/0102; **KK26** Civil Party application 09-VU-04265, D22/0274 (collectively "OCP's Requests"), dated 6 January 2009, D274/2។

[3] **VN01** Civil Party application 08-VU-02379 (accepted as a Civil Party on 18 August 2009 Ref: D22/125/3); **VN02** Civil Party application 08-VU-02380 (accepted as a Civil Party on 1 September 2009 Ref: D22/171/4); **VN03** Civil Party application 08-VU-02378; **VN04** Civil Party application 08-VU-02116 (accepted as a Civil Party on 2 October 2009 Ref: D22/171/2); **VN05** Civil Party application 09-VU-01723; **VN06** Civil Party application 09-VU-01722; **VN07** Civil Party application 09-VU-02241; **VN08** Civil Party application 09-VU-02242; **VN09** Civil Party application 09-VU02243; **VN10** Civil Party application 09-VU-02291 (accepted as a Civil Party on 4 December 2009 Ref: D22/205/2); **VN11** Civil Party application 09-VU-02239; **VN12** Civil Party application 09-VU-02240; **VN13** Civil Party application 09-VU-00687; **VN14** Civil Party application 09-VU-00686; **VN15** Civil Party application 09-VU-00688; **VN16** Civil Party application 09-VU-00685 ។

សាសន៍ចំពោះខ្មែរកម្ពុជាក្រោម និងវៀតណាម (“ដីការួមគ្នា”)[4] ដែលច្រានចោលនូវសំណើឯករាជ្យ និងដាច់ដោយឡែកសម្រាប់ការស៊ើបអង្កេត ដែលបានដាក់ដោយការិយាល័យសហព្រះរាជអាជ្ញា (“OCP”)[5] និងសហមេធាវី[6]។ បើយោងទៅតាមអង្គហេតុ និងអង្គច្បាប់ ការិយាល័យសហចៅក្រមស៊ើបអង្កេតមានកំហុសក្នុងការច្រានចោលនូវសំណើទាំងនេះ ដែលសំណើទាំងនេះពិតជាមានសារៈសំខាន់ក្នុងការគាំទ្រដល់កិច្ចស៊ើបអង្កេតដែលកំពុងតែដំណើរការពាក់ព័ន្ធនឹងសំណុំរឿង002/19-09-2007/ECCC/OCIJ (“សំណុំរឿង០០២”)។ បណ្តឹងឧទ្ធរណ៍នេះមានរួមបញ្ចូលនូវទឡ្ហីករណ៍ដែលបានលើកឡើងក្នុងសារណារបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីដាច់ដោយឡែកមួយ តែពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតស្តីពីភាពនៃអាចទទួលយកបាននូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាក់ទិននឹងសំណើ D250/3 (“ដីកាស្តីពីភាពអាចទទួលយកបាន”)[7] ។

បណ្តឹងឧទ្ធរណ៍នេះគឺត្រូវបានរៀបចំរួមគ្នាដោយសហមេធាវីអន្តរជាតិ Silke STUDZINSKY ជួសមុខឱ្យកូនក្តីដែលជាដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់ គឺអ្នកដែលអាចប្រឈមនឹងការដកហូតឋានៈរបស់ខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកដែលនឹងមិនត្រូវបានផ្តល់ឱកាសឱ្យក្លាយជាដើមបណ្តឹងរដ្ឋប្បវេណី ដែលនេះជាករណីដែលទំនងនឹងកើតមាន និងក្នុងស្ថានភាពមួយដែលថា ពួកគេនឹងត្រូវបានសម្រេចថាស្ថិតនៅក្រៅវិសាលភាពនៃការស៊ើបអង្កេត

[4] ដីកាសម្រេចរួមលើសំណើសុំបំពេញកិច្ចស៊ើបសួរពីររបស់សហព្រះរាជអាជ្ញាទាក់ទងនឹងខ្មែរក្រោម និងការសំលាប់រង្គាលនៅស្រុកបាកាន(ខេត្តពោធិ៍សាត់)ព្រមទាំងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរបន្ថែមរបស់ដើមបណ្តឹងរដ្ឋប្បវេណីពាក់ពន្ធ័នឹងអំពីប្រល័យពូជសាសន៍លើខ្មែរក្រោម និងជនជាតិវៀតណាម ចុះថ្ងៃទី១៣.មករា.២០១០ , D250/3/3។

[5] សំណើរបស់សហព្រះរាជអាជអាជ្ញាសុំបំពេញកិច្ចស៊ើបសួរទាក់ទងនឹងខ្មែរក្រោម និងការសំលាប់រង្គាលក្នុងស្រុកបាកាន (ខេត្តពោធិ៍សាត់) ចុះថ្ងៃទី១១ ធ្នូ ២០០៩ D274 និងសំណើសុំបំពេញកិច្ចស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងទៅនឹងខ្មែរក្រោម(សំណើរបស់សហព្រះរាជអាជ្ញារួមគ្នា) ចុះថ្ងៃទី ០៦ មករា ២០០៩ ឯកសារ D274/2។

[6] សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំបំពេញកិច្ចស៊ើបសួរបន្ថែមទាក់ទងនឹងអំពើប្រល័យពូជសាសន៍ទៅលើខ្មែរក្រោមនិងជនជាតិវៀតណាម (សំណើរបស់សហមេធាវី) ចុះថ្ងៃទី០៣ ធ្នូ ២០០៩ ឯកសារ D50/3។

[7]ដីកាស្តីពីភាពអាចទទួលយកបាននៃសំណើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលពាក់ពន្ធ័ទៅនឹងសំណើសុំ D250/3។

ដូចបានកំណត់ដោយសហចៅក្រមស៊ើបអង្កេត។ ដូច្នេះ កូនក្តីទាំងនេះមានចំណាប់អារម្មណ៍ដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងលទ្ធផលនេះដែលជាបណ្តឹងឧទ្ធរណ៍ដំបូងគេបង្អស់ដូចមានចែងក្នុងវិធាន ៧៤ (៤)(ក)ពាក់ព័ន្ធនឹងដីកាស្តីពីការទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ អនុលោមទៅតាមវិធាន៧៧(៦) សហមេធាវីសុំស្នើដោយគោរពថា បណ្តឹងឧទ្ធរណ៍ទាំងនេះត្រូវបានបញ្ចូលគ្នា និងធ្វើការពិភាក្សាដេញដោលនៅក្នុងសវនាការជាសាធារណៈមួយ ដោយអង្គបុរេជំនុំជម្រះសម្រាប់មូលហេតុចម្បងៗដូចខាងក្រោម៖

ក. ជាបណ្តឹងគឺមិនធ្លាប់មានពីមុនមក ជាប្រភេទបណ្តឹងឧទ្ធរណ៍ដំបូងគេបង្អស់ពាក់ព័ន្ធនឹងដីកាដែលចេញដោយសហចៅក្រមស៊ើបអង្កេតធ្វើការបដិសេធដល់សំណើសុំធ្វើការស៊ើបអង្កេតទាក់ទិននឹងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ចំពោះក្រុមគោលដៅ។

ខ. បណ្តឹងឧទ្ធរណ៍ទាំងនេះលើកឡើងនូវបញ្ហាផលប្រយោជន៍សាធារណៈ ដែលត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយដោយប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុក។

គ. បើពិចារណាទៅលើភាពចាំបាច់វិញ បណ្តឹងឧទ្ធរណ៍ទាំងនេះជួយសម្រួលដល់ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមកពីខេត្តឆ្ងាយៗ គឺថាសវនាការជាសាធារណៈមួយ ដែលអាចត្រូវបានផ្សាយបន្តជូនសម្រាប់អ្នកដាក់ពាក្យទាំងនេះគឺពិតជាបង្ហាញពីផលប្រយោជន៍នៃយុត្តិធម៌។

ឃ. បើពិចារណាថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះនឹងកំណត់ច្បាស់លាស់អំពីតួនាទីរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២នោះ សវនាការជាសាធារណៈមួយគឺពិតជាបង្ហាញពីផលប្រយោជន៍នៃយុត្តិធម៌។

ង. បញ្ហាដូចដែលបានលើកឡើងក្នុងបណ្តឹងឧទ្ធរណ៍ទាំងនេះនឹងទៅជាស្ថាពរដោយសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ។

ច. បណ្តឹងឧទ្ធរណ៍ទាំងនេះទាក់ទិននឹងយុត្តាធិការរបស់អ.វ.ត.ក ដោយវាពាក់ព័ន្ធនឹងឆន្ទានុសិទ្ធិផ្នែកកិច្ចការស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេត។

ឆ. សវនាការជាសាធារណៈមួយនឹងមិនប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬវិធានការការពារណាមួយដែលរៀបចំដោយតុលាការឡើយ។

## II. សេចក្ដីសង្ខេបនៃអង្គហេតុ

១. ដើម្បីជៀសវាងភាពច្រំដែល អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីជនជាតិវៀតណាមឯកភាពបញ្ចូលរួមគ្នានូវអង្គហេតុនានា ដែលលើកឡើងដោយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីខ្មែរកម្ពុជាក្រោម ទាក់ទិននឹងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ("IS") របស់ការិយាល័យសហព្រះរាជអាជ្ញា និងអង្គហេតុផ្សេងៗទៀតទាក់ទិននឹងឧក្រិដ្ឋកម្មប្រឆាំងនឹងជនជាតិវៀតណាម និងឧក្រិដ្ឋកម្មនានាអនុវត្តដោយវៀតណាម។

២. ផ្ទុយទៅនឹងដីកាសម្រេចរួមនេះ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីខ្មែរកម្ពុជាក្រោម និងដើមបណ្ដឹងរដ្ឋប្បវេណី នឹងបង្ហាញថា៖

ក. សំណើរបស់សហព្រះរាជអាជ្ញា និង/សហមេធាវីស្ថិតក្នុងវិសាលភាពនៃកិច្ចស៊ើបអង្កេត។

i. ការិយាល័យសហចៅក្រមស៊ើបអង្កេតគឺដឹងឮអំពីឧក្រិដ្ឋកម្មប្រឆាំងនឹងជនជាតិវៀតណាម និង(ដោយទំនាក់ទំនង) ខ្មែរក្រោម បើយោងទៅតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ការយកចម្លើយរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតពីខ្មែរក្រោម និងជនជាតិវៀតណាម ក្នុងពេលស៊ើបអង្កេត និងអង្គហេតុថ្មីៗក្នុងទម្រង់ជាទិន្នន័យសោតទស្សន៍ និងសំអាងលើបទពិសោធន៍ ដែលការិយាល័យសហចៅក្រមស៊ើបអង្កេតបានទទួលពីសហមេធាវី។

ii. សំណើរបស់សហមេធាវីគាំទ្រដល់ការស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតឱ្យមាន "ភស្តុតាងច្បាស់លាស់ និងស្របគ្នា" ពាក់ព័ន្ធនឹងគោលនយោបាលរបស់បក្សកុម្មុយនីយកម្ពុជា ("CPK") ក្នុងការរើសអើង និងបំបាត់ជនជាតិវៀតណាម និងអ្នកជាប់ខ្សែវៀតណាម[8]។

[8] *Id.* at para. 4.

iii. វិសាលភាពនៃកិច្ចស៊ើបអង្កេតសម្រាប់ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មផ្សេងៗទៀតប្រឆាំងនឹងមនុស្សជាតិ ដែលបានសំអាងទៅលើសមាសធាតុមួយនៃការធ្វើទុក្ខបុកម្នេញលើក្រុមគោលដៅ(ដូចជាជនជាតិវៀតណាម និងខ្មែរក្រោម) មិនគួរកម្រិតត្រឹមទីតាំងភូមិសាស្ត្រជាក់លាក់ឡើយ។ ក្នុងករណីនេះ ចរិត និងវិសាលភាពនៃការនៅឆ្ងាយរបស់ឧក្រិដ្ឋកម្មគួរផ្តល់ធ្វើកិច្ចស៊ើបសួរ។

ខ. សហចៅក្រមស៊ើបអង្កេតអាចស៊ើបសួរចំពោះអង្គហេតុដែលកំណត់ដោយសំណើទាំងឡាយរបស់សហព្រះរាជអាជ្ញានៅពេលដែលគាត់បានរួមបញ្ចូលទៅជាក្នុងរូបភាពដោយឡែក ឬ/និងជាមួយគ្នាជាដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមមុននោះ។

i. សំណើទាំងនេះមានភាពសមស្របទៅនឹងខ្លឹមសារជាផ្លូវការនៃដីកាបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមក្រោមវិធានផ្ទៃក្នុង។

ii. ក.ស.ច.ស បានភាន់ច្រលំអំពីកម្មវត្ថុនៃច្បាប់ដែលបានកំណត់ថា មាត្រា ៣.២ (ជ)នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសាររបស់ អ.វ.ត.ក ឆ្នាំ២០០៧ កែសម្រួលលើកទី៤ (សេចក្តីណែនាំអនុវត្ត[9]) មានខ្លឹមសារច្រានចោលសំណើពីដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម។

iii. សំណើនេះបំពេញសេចក្តីត្រូវការដ៏សំខាន់សំរាប់ដីកាបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមក្រោមវិធាន ៥៣ (១) និងមាត្រា ៤.១ នៃសេចក្តីណែនាំអនុវត្តនេះ។

iv. ក.ស.ច.ស បានទទួលជាផ្លូវការនូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងប្រឆាំងនឹងដើមបណ្តឹងរដ្ឋប្បវេណីខ្មែរក្រោម និងអ្នកដាក់ពាក្យបណ្តឹងតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅស្រុកបាកានតាមរយៈសំណើនេះ។

គ. ក.ស.ច.ស អាចស៊ើបអង្កេតអង្គហេតុដែលបានលើកឡើងនៅក្នុងសំណើរបស់សហមេធាវីដែលនៅដោយឡែក និងឯករាជពីសំណើរបស់សហព្រះរាជអាជ្ញា

[9] ដីកាសម្រេចរួម កឋាខណ្ឌទី៦ ។

i. សំណើរបស់សហមេធាវីបង្ហាញឱ្យឃើញមានឧក្រិដ្ឋកម្ម "ក្នុងយុត្តាធិការរបស់ អ.វ.ត.ក" ដែល ក.ស.ច.ស ត្រូវស៊ើបអង្កេតអនុលោមតាមវិធាន ២៣(១)(ក) និងវិធាន ៥៥(១)

ii. ក.ស.ច.ស មិនបានអនុវត្តវិធាន៥៥ទេ ដោយគាត់លើកឡើងថា គាត់មិនមានអំណាចតាមផ្លូវច្បាប់ណាមួយក្នុងការស៊ើបអង្កេតអង្គហេតុដែលមាននៅក្នុងសំណើនេះ។

iii. សហមេធាវីបានដាក់ជូនដាច់ដោយឡែកនូវ "អង្គហេតុថ្មី" ក្នុងទំរង់របាយការជាក់លាក់ និងទិន្នន័យដែលអាចមើលឃើញនិងស្តាប់បាន ដែល ក.ស.ច.ស មិនបានស៊ើបអង្កេត និង/ឬបញ្ជូនទៅសហព្រះរាជអាជ្ញាដើម្បីការស៊ើបសួរក្រោមវិធាន៥៥(៣)។

iv. អង្គហេតុថ្មីទាំងនេះត្រូវបានដាក់ជូនបន្ថែមតាមរយៈសំណើរបស់សហព្រះរាជអាជ្ញាដោយគំនិតផ្តួចផ្តើមផ្ទាល់របស់ខ្លួនដែលរួមបញ្ចូលជាដីកាបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។

v. ក.ស.ច.ស ទទួលស្គាល់ថាគាត់បានជួបប្រទះ "អង្គហេតុថ្មី" នៅក្នុងដំណើនៃកិច្ចសម្ភាសន៍សាក្សីជាមួយនឹងប្រជាពលរដ្ឋខ្មែរក្រោម ប៉ុន្តែគាត់មិនបានពិនិត្យភស្តុតាងនេះ ហើយក៏មិនបានពិចារណាចំពោះការស៊ើបអង្កេតបន្ថែមទាក់ទងសំណើរបស់សហមេធាវី ឬរបស់សហព្រះរាជអាជ្ញានោះទេ។

vi. ការកំណត់ដោយបំពានអំពីវិសាលភាពនៃកិច្ចស៊ើបអង្កេតនៃតុលាការរបស់ ក.ស.ច.ស ត្រូវបានកំរិតដោយវិសាលភាពនៃការស៊ើបអង្កេតចោទប្រកាន់ មិនមែនជាការស៊ើបអង្កេតនៃតុលាការរបស់ ក.ស.ច.ស នោះទេ ដែលនឹងត្រូវសម្រេចនៅក្នុងដីកាដំណោះស្រាយក្រោមវិធាន ៦៧ ដែលបានកាត់បន្ថយសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។

vii. សេចក្តីដែលមិនបានពន្យល់របស់សហព្រះរាជអាជ្ញាចំពោះចំនងនៃឯកសារដែលថាជា "សំណើសុំបំពេញកិច្ចស៊ើបសួរ" ជាជាង "ដីកាបំពេញកិច្ចស៊ើបសួរ" គឺជាការខុសប្លែកគ្នានូវទម្រង់ ហើយមិនគួរត្រូវបានគេអនុញ្ញាតឱ្យមានការកាត់បន្ថយសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីនោះទេ។

ឃ. តាមរយៈការកំរិតចំពោះការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅ អ.វ.ត.កនោះ អ.វ.ត.ក នឹងបំពាននូវគោលការណ៍ជាមូលដ្ឋានរបស់ខ្លួន។

i. ដីកាសម្រេចរួម កាត់បន្ថយនូវសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីផ្ទុយទៅនឹងសិទ្ធិទទួលបាននូវការពិត និងយុត្តិធម៌ដែលជាប់ពាក់ព័ន្ធនឹងពួកគេ។

ii. ដីកាសម្រេចរួមបានបំពាននូវគោលបំណងដែលបានលើកឡើងរបស់ អ.វ.ត.ក ដែលអនុញ្ញាតឱ្យមានការដាក់បណ្តឹងជាដើមបណ្តឹងរដ្ឋប្បវេណីជាមធ្យោបាយក្នុងការទទួលស្គាល់តម្រូវការឱ្យមានការផ្សះផ្សារនិងការបង្រួមបង្រួមជាតិ។

iii. ដីកាសម្រេចរួមផ្តល់ការចាប់អារម្មណ៍ដែលថា ដំណើរការរបស់ដើមបណ្តឹងរដ្ឋប្បវេណីគឺត្រូវបានសំរិតសម្រាំង និងបំពាន ដោយមានហេតុផលតិចតួចសំរាប់ការចូលរួមរបស់ជនរងគ្រោះដែលបានចូលរួមយ៉ាងសកម្មឆ្លើយតបទៅនឹងការឈឺចាប់របស់ពួកគេ។

iv. ដីកាសម្រេចរួមបានដកចេញខ្មែរកម្ពុជាក្រោមពីកំណត់ត្រានៃទំព័រជាប្រវត្តិសាស្ត្រនិងផ្លូវច្បាប់ចេញពី អ.វ.ត.ក ដោយបដិសេធនូវការឈឺចាប់របស់គេជាក្រុមមួយ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

v. ដីកាសម្រេចរួមបានរំលោភទៅលើបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិដែលការពារសិទ្ធិរបស់ជនរងគ្រោះ។

## III. ខន្លីករណ៍

### ក. សំណើរបស់សហព្រះរាជអាជ្ញា និងសហមេធាវីគឺស្ថិតនៅក្នុងវិសាលភាពនៃកិច្ចស៊ើបសួរតាមផ្លូវតុលាការ

១. ក.ស.ច.ស បានដឹងអំពីឧក្រិដ្ឋកម្មប្រឆាំងនឹងជនជាតិវៀតណាម និងខ្មែរក្រោមតាមរយៈតាមរយៈការជាប់ពាក់ព័ន្ធរបស់គេ ទៅតាមដីកាបញ្ជូនរឿងឱ្យស៊ើបសួរ។ ដីកាបញ្ជូនរឿងឱ្យស៊ើបសួរបញ្ជាក់ថា ជនត្រូវចោទបានអនុវត្ត "គោលនយោបាយនៃការរើសអើង និងសំលាប់ជនជាតិភាគតិចវៀតណាម...... ដែលធ្វើចលនាមួយលុបបំបាត់អ្នកទាំងអស់នោះដោយសារតែពួកគេមានជាប់ពាក់ពន្ធ័ជាមួយនឹងប្រទេសវៀតណាម"[10]។

២. សំណើរបស់សហព្រះរាជអាជ្ញា និងសហមេធាវីបានបញ្ជាក់ថា ខ្មែរក្រោមដែលមកពីវៀតណាមខាងត្បូង (កម្ពុជាក្រោម) គឺជាគោលដៅនៃការលំបំបាត់ចោលដោយសារការ ជាប់ពាក់ពន្ធ័របស់គេជាមួយប្រទេសវៀតណាម ហើយការចោទប្រកាន់នោះ គួរត្រូវបានធ្វើឡើងទៅតាមឧក្រិដ្ឋកម្មទាំងឡាយដែលប្រជាពលរដ្ឋទាំងនេះបានទទួលរង។ ជាពិសេសនោះ សហព្រះរាជអាជ្ញាបានបន្ថែមថា "ខ្មែរក្រោមត្រូវបានសំលាប់ដោយបក្សកម្មុយនីសកម្ពុជាប្រជាធិបតេយ្យដោយសារតែពួកគេមានជាប់ពាក់ពន្ធ័ជាមួយនឹងប្រទេសវៀតណាម"[11]។ នៅក្នុងសំណើនេះ សហមេធាវីបានលើកហេតុផលនូវភស្តុតាងដោយកត់សំគាល់ថា ខ្មែរក្រហមយល់ថាខ្មែរក្រោម "មានជាប់ពាក់ពន្ធ័ក្នុងរូបភាពជាអ្នកដែលមានសញ្ជាតិ និង/ឬជាជនជាតិភាគតិចរបស់វៀតណាម"[12] និងបានទទួលរងនូវការធ្វើទុក្ខបុកម្នេញក្រោមគោលនយោបាយប្រល័យពូជសាសន៍ដូចគ្នាបំផុតដែល នាំឱ្យសហាចៅក្រមស៊ើបអង្កេតធ្វើការស្នើសុំនៅក្នុងដីកាបញ្ជូនរឿងស៊ើប

---

[10] ដីកាបញ្ជូនរឿងឱ្យស៊ើបសួរ ចុះថ្ងៃទី ១៨ កក្កដា ២០០៧ ឯកសារ D2 កឋាខណ្ឌ១២(ច)។

[11] D274 កឋាខណ្ឌទី ៥ ។

[12] សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំបំពេញកិច្ចស៊ើបសួរបន្ថែមទាក់ទងនឹងអំពើប្រល័យពូជសាសន៍ទៅលើខ្មែរក្រោម និង ជនជាតិវៀតណាម (សំណើរបស់សហមេធាវី) ចុះថ្ងៃទី០៣ ធ្នូ ២០០៩ ឯកសារ D50/3 កឋាខណ្ឌ ៣។

សួររបស់ខ្លួនឲ្យមានការចោទប្រកាន់អំពីអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ប្រឆាំងទៅនឹងជនត្រូវចោទទាំងឡាយតាងនាមឲ្យក្រុមជនជាតិភាគតិចដែលមាន សញ្ជាតិជាវៀតណាម[13]។

៣. រឿងក្តីដែលលើកឡើងដោយសហមេធាវី និង/ឬដោយសហព្រះរាជអាជ្ញា បង្ហាញឲ្យឃើញឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ដោយរាប់បញ្ចូលទាំងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[14] ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងសឺណែវឆ្នាំ ១៩៤៩ និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍[15] និងឧក្រិដ្ឋកម្មថ្នាក់ជាតិ[16]។ ក.ស.ច.ស មិនត្រឹមតែមិនបានបញ្ជាក់ការចោទប្រកាន់[17]ទាំងនោះទេ ប៉ុន្តែក៏មិនបានជំទាស់ទេទៅនឹងអង្គហេតុដែលថា ខ្មែរក្រោមគឺជា "ក្រុមគោលដៅ[18]"ដោយឡែកមួយនោះ និង/ឬជាក្រុមមួយដែលមានចំណងទាក់ទងយ៉ាងពិតប្រាកដច្បាស់លាស់ និងដែលត្រូវបានដឹង ជាមួយនឹងប្រទេសវៀតណាម ជាជាងនូវអ្វីដែលត្រឹមតែចង្អុលបញ្ជាក់ថាខ្មែរក្រោមគឺជាជន "ជាតិភាគតិច"[19]មួយនោះ។

---

[13] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ កថាខ័ណ្ឌទី ១២២(ខ)-(គ)។

[14] ច្បាស់ស្តីពី អ.វ.ត.ក មាត្រា៥ មាត្រា ២៩ (ថ្មី) និងមាត្រា ៣៩ (ថ្មី)។

[15] ច្បាស់ស្តីពី អ.វ.ត.ក មាត្រា៤ មាត្រា ២៩ (ថ្មី) និងមាត្រា ៣៩ (ថ្មី)។

[16] ច្បាស់ស្តីពី អ.វ.ត.ក មាត្រា៣ មាត្រា ២៩ (ថ្មី) និងមាត្រា ៣៩ (ថ្មី)។

[17] សូមមើលកំណត់ហេតុស្តាប់ចម្លើយជនត្រូវចោទ (នួន ជា) ("កំណត់ហេតុស្តាប់ចម្លើយ") ចុះថ្ងៃទី១៥ ធ្នូ ២០០៩ ឯកសារលេខ D75 កឋាខណ្ឌទី ៤ និងទី ១៣។

[18] កំណត់ហេតុស្តាប់ចម្លើយជនត្រូវចោទ (នួន ជា) ("កំណត់ហេតុស្តាប់ចម្លើយ") ចុះថ្ងៃទី១៥ ធ្នូ ២០០៩ ឯកសារលេខ D75 កឋាខណ្ឌទី ៤ ( តាមរយៈការពិនិត្យឡើងវិញនូវភស្តុតាងនៃសហករណ៍ និងទីកន្លែងធ្វើការងារ មន្ទីរសន្តិសុខ និងទីកន្លែងសំលាប់មនុស្ស ការកើតមានឡើងនូវការដាក់មនុស្ស និងការប្រព្រឹត្តទៅលើក្រុមជាក់លាក់នានា ដូចជា ចាម វៀតណាម ក្រុមសាសនា និងក្រុមដែលជាគោលដៅដទៃទៀត យើងយល់ឃើញថា វាមានភស្តុតាងច្បាស់លាស់ដែលនាំឲ្យមានការរួមបញ្ចូល ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងសឺណែវ ឆ្នាំ១៩៤៩ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋថ្នាក់ជាតិដែលត្រូវបានប្រព្រឹត្តឡើង" (បញ្ជាក់បន្ថែម)។

[19]ដីកាស្តីពីសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំបន្ថែមទំពរ័សំរាប់ដាក់សារណាសុំបំពេញកិច្ចស៊ើបសួរបន្ថែម កាលពីថ្ងៃទី ០៣ ធ្នូ ២០០៩ ឯកសារ D២៥០/2 កឋាខ័ណ្ឌទី៥ ។

៤. វាគួរតែថា ឧក្រិដ្ឋកម្មដែលត្រូវបានលើកបង្ហាញដោយភស្តុតាងរបស់សហព្រះរាជអាជ្ញា និងសហមេធាវីគឺទាមទារឱ្យមានកិច្ចស៊ើបអង្កេតតាមផ្លូវតុលាការដោយខានមិនបាន[20] ។ ទោះជាយ៉ាងនេះ ក.ស.ច.ស បានបដិសេធក្នុងការទទួលអនុវត្តនូវកិច្ចស៊ើបសួរតាមដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឬក៏ពិចារណាថាតើវាមានភាពចាំបាច់ក្នុងការបើកកិច្ចស៊ើបសួរតាមផ្លូវតុលាការក្រោមវិធាន៥៥(១០)ឬយ៉ាងណា[21] សូម្បីតែការចោទប្រកាន់ជនត្រូវចោទចំពោះឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តប្រឆាំងនឹងជនជាតិភាគតិច/ក្រុមដែលមានសញ្ជាតិជាវៀតណាមដែលអ្នកទាំងនោះគឺជាដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី[22]។

៥. សំណើរបស់សហមេធាវីគាំទ្រនូវការស៊ើបសួររបស់ ក.ស.ច.ស ដើម្បីទទួលបាននូវភស្តុតាងច្បាស់លាស់ និងស្រប់គ្នាទាក់ទងទៅនឹងគោលនយោបាយរបស់បក្សកុម្មុយនីសកម្ពុជាក្នុងការរើសអើង និងលុបបំបាត់គ្រប់ជនជាតិវៀតណាម និងជនដទៃទៀតដែលជាប់ទាក់ទងជនជាតិវៀតណាមនោះ[23]។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរគ្រាន់តែកំណត់អត្តសញ្ញាណចំពោះទីតាំងទាំងឡាយដែលអង្គហេតុមួយចំនួននៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានប្រព្រឹត្តឡើង ភស្តុតាងនៃគោលនយោបាយជាមូលដ្ឋានគឺមានភាពទូលំទូលាយ ហើយមិនបានកំរិតដែនកំណត់ត្រឹមតែចំពោះតំបន់ជាក់លាក់ដែលត្រូវបានលើកឡើងឱ្យបើកកិច្ចស៊ើបសួរដោយសហព្រះរាជអាជ្ញាកាលពីថ្ងៃទី ១៨ កក្កដា ២០០៧នោះទេ។ សំរាប់ហេតុផលនេះ បណ្តឹងនៃឧក្រិដ្ឋកម្មបន្ថែមដែលត្រូវបានលើកឡើងដោយអ្នកដាក់ពាក្យសុំតាំងខ្លួនជា

---

[20] វិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ឆ្នាំ២០០៧ កែសម្រួលលើកទី៤ ចំនុច ៥៣(៣)។

[21] វិធាន ៥៥ (១០)។

[22] កំណត់ហេតុស្តាប់ចម្លើយជនត្រូវចោទ (នួន ជា) ("កំណត់ហេតុស្តាប់ចម្លើយ") ចុះថ្ងៃទី១៥ ធ្នូ ២០០៩ ឯកសារលេខ D២75 កឋាខណ្ឌទី ១៣ ។

[23] ដីកាបញ្ជូនរឿងឱ្យស៊ើបសួរ កឋាខ័ណ្ឌទី ១២(១)។

ដើមបណ្ដឹងរដ្ឋប្បវេណីជាវៀតណាម និងខ្មែរក្រោមដែលធ្វើឡើងរៀងៗខ្លួន គឺស្ថិតនៅក្នុងវិសាលភាពនៃកិច្ចស៊ើបសួរយ៉ាងពិតប្រាកដ ពីព្រោះពួកគាត់ជួយធ្វើការបង្ហាញភស្តុតាងចំពោះការធ្វើទុក្ខបុកម្នេញចំពោះជនជាតិវៀតណាមនិងខ្មែរក្រោម។ លើសពីនេះទៅទៀត ដូចដែរភស្តុតាងនៃភាពឃោរឃៅដែលត្រូវបានប្រព្រឹត្តឡើងលើខ្មែរក្រោមបាននិយាយចំចំនុចនៃអត្ថិភាពនៃគោលនយោបាយប្រល័យពូជសាសន៍/ធ្វើទុក្ខបុកម្នេញនោះ សំណើរបស់សហព្រះរាជអាជ្ញា និងសហមេធាវី គឺស្ថិតនៅក្នុងវិសាលភាពនៃកិច្ចស៊ើបសួរយ៉ាពិតប្រាកដ។

៦. វិសាលភាពនៃកិច្ចស៊ើបសួរនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មដទៃៗទៀតដែលបានសំអាងទៅលើធាតុផ្សំនៃការធ្វើទុក្ខបុកម្នេញចំពោះក្រុមដែលជាគោលដៅមិនគួរត្រូវបានកំរិតតែចំពោះខេត្តដែលបានលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនោះទេ។ ក្នុងករណីទាំងនេះ ចរិតលក្ខណះ និងវិសាលភាពនៃឧក្រិដ្ឋកម្មគួរជូនដំណឹងអំពីការស៊ើបអង្កេត។ ដូច្នេះ ក.ស.ច.សបានធ្វើខុស ចំពោះការអនុវត្តកិច្ចស៊ើបសួរនេះ ក្នុងការប្រព្រឹត្តទៅលើខ្មែរក្រោម និងជនជាតិភាគតិចវៀតណាមនៅក្នុងតំបន់ភូមិសាសន៍ដែលមិនស្ថិតនៅក្នុងវិសាលភាពនៃដីកាបញ្ជូនរឿងឲ្យស៊ើបសួរ[24] ថានៅក្រៅនៃយុត្តាធិការ។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរមិនលើកឡើងអស់នោះទេ ប៉ុន្តែគ្រាន់តែលើកឡើងនូវបណ្ដឹងឧក្រិដ្ឋកម្មជាក់លាក់[25]ថាជាភស្តុតាងនៃគោលនយោបាយប្រល័យពូជសាសន៍ជាតិរបស់បក្សកុម្មុយនីសកម្ពុជាប្រឆាំងទៅនឹងក្រុមមនុស្សដែលជាគោលដៅ។

៧. តាមរយៈនិយមន័យរបស់វា ឧក្រិដ្ឋកម្មធ្វើទុក្ខបុកម្នេញដ៏ឃោរឃៅ តួយ៉ាងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិគឺជាឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តផ្ទាល់ប្រឆាំងទៅនឹងក្រុមមនុស្សគោលដៅជាជាងប្រឆាំងទៅនឹងវង្វង់ដែនដីពិសេសណាមួយ។ ភស្តុតាងនៃផែនការមួយដែលដាក់ទិសដៅទៅលើក្រុមទាំងនោះ មិន

[24] ដីកាសម្រេចរួម កឋាខ័ណ្ឌ ៩ ។

[25] ដីកាបញ្ជូនរឿងឲ្យស៊ើបសួរ កឋាខណ្ឌទី ៦៩ និង៧០។

អាចកម្រិតត្រឹមភូមិសាស្ត្រទេ។ ឧទាហរណ៍ នៅក្នុងសំណុំរឿងព្រះរាជអាជ្ញាទល់នឹង Milosevic តុលាការព្រហ្មទណ្ឌអន្តរជាតិសំរាប់អតីតប្រទេសយូហ្គោស្លាវី អង្គជំនុំជម្រះបានកត់សំគាល់ថា ចេតនានៃអំពើប្រល័យពូជសាសន៍របស់អ្នកដឹកនាំ Bosnian Serb អាចត្រូវបានយល់ឃើញពីភស្តុតាងដែលត្រូវបានប្រមូលចេញពីទីក្រុងផ្សេងគ្នាចំនួន៧[26]។ ស្រដៀងគ្នានេះដែរ ការកំរិតតំបន់ភូមិសាស្ត្រដែលឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានប្រព្រឹត្តឡើងនឹងឡងមកវិញចំពោះសេចក្តីត្រូវការជានីត្យានុកូលកើតមានចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងទម្រង់យ៉ាងធំទូលំទូលាយ និងជារចនាសម្ព័ន្ធ[27]។ ក.ស.ច.ស មានកំហុសក្នុងបញ្ហាអង្គហេតុ និងអង្គច្បាប់ដោយបានបដិសេធចោលនូវសំណើរបស់សហព្រះរាជអាជ្ញា និងសហមេធាវីដោយផ្អែកលើមូលដ្ឋានដែលថា សំណើទាំងនេះ មិនស្ថិតនៅក្នុងវិសាលភាពដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់សហព្រះរាជអាជ្ញាខ្លួនឯង។

## ខ. ក.ស.ច.ស អាចបើកកិច្ចស៊ើបសួរបន្ថែមអនុលោមតាមសំណើរបស់សហព្រះរាជអាជ្ញាពេលដែលគាត់ដាក់រួមបញ្ចូលជាដីកាបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម

៨. សំណើរបស់សហព្រះរាជអាជ្ញាបានរួមបញ្ចូលជាដីការបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ( ក្នុងទម្រង់ និងក្នុងខ្លឹមសារ) ដែលពង្រីកនូវវិសាលភាពនៃដីកាបញ្ជូនរឿងឲ្យស៊ើបសួរដើម្បីរាប់បញ្ចូលជនជាតិភាគតិចខ្មែរក្រោមនៅក្នុងស្រុកបាកាន ខេត្តពោធិ៍សាត់។ សំណើរបស់សហព្រះរាជអាជ្ញាមានការជាប់ទាក់ទងយ៉ាងរឹងមាំទៅនឹងខ្លឹមសារជាផ្លូវការនៃដីកាបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង។ អនុលោមតាមសន្ទានុក្រមនៃវិធានផ្ទៃក្នុង ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមគឺ "ផ្អែកទៅលើលិខិតជាលាយល័ក្ខណ៍អក្សរដែលធ្វើឡើងដោយសហព្រះរាជអាជ្ញាស្នើសុំទៅសហចៅ

[26] *Prosecutor v. Milosevic*, "Decision on Motion for Judgment of Acquittal," Case No. IT-02-54-T, 16 June 2004, para. 246.

[27] ច្បាប់ស្តីពី អ.វ.ត.ក ក មាត្រា ៥ ។

ក្រុមស៊ើបអង្កេតដើម្បីចេញនូវដីកា ឬ ទទួលធ្វើសកម្មភាពបន្ថែមនៅក្នុងកិច្ចស៊ើបអង្កេតដែលកំពុងដំណើរការ”[28]។ សំណើរបស់សហព្រះរាជអាជ្ញាគឺសមស្របយ៉ាងខ្លាំងទៅនឹងការលើកឡើង ដែលបានជំរុញយ៉ាងច្បាស់លាស់ទៅ ក.ស.ច.ស ឱ្យបំពេញកិច្ចស៊ើបសួរបន្ថែមទៅលើកិច្ចស៊ើបសួរដែលកំពុងដំណើរការ[29]។

៩. ក.ស.ច.ស បានលើកឡើងជាច្រើនដងនៅក្នុងដីកាសម្រេចរួមរបស់ខ្លួន ដោយកត់សំគាល់ថា សហព្រះរាជអាជ្ញាបានដាក់ជូននូវសំណើសុំបំពេញកិច្ចស៊ើបសួរបន្ថែម ក្រោមវិធាន៥៥(១០) ដោយស្នើទៅ ក.ស.ច.ស ឱ្យធ្វើការស៊ើបសួរយ៉ាងត្រឹមត្រូវទៅលើឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ហើយដែលបានប្រព្រឹត្តឡើងប្រឆាំងប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោមនៅក្នុងស្រុកបាកាន ខេត្តពោធិ៍សាត់[30]។ ទោះបីជាយ៉ាងណាក៏ដោយ ក.ស.ច.ស មិនបានពិចារណាថាតើការលើកឡើងនៅក្នុងសំណើខាងលើនេះបានសម្តែងនូវខ្លឹមសារជាផ្លូវការនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ឬយ៉ាងណានោះទេ។ ដូច្នេះហើយ វាក៏មិនប្រាកដផងដែរថាតើ ក.ស.ច.ស បានធ្វើការសម្រេច ឬអត់ ដែលថាសំណើរបស់សហព្រះរាជអាជ្ញាអាចត្រូវបានយកមកពិចារណាថាជាដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ឬយ៉ាងណានោះទេ[31]។

១០. ក.ស.ច.ស បានណែនាំខុសដោយខ្លួនឯងក្នុងការកំណត់ថា មាត្រា ៣.២ (ជ)នៃសេចក្តីណែនាំអនុវត្តទាមទារថា ការដាក់ជូនដោយសហព្រះរាជអាជ្ញាដែលអះអាងថាជា ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាដីបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមត្រូវតែមានចែង

---

[28] សន្ទានុក្រម នៃវិធានផ្ទៃក្នុង

[29] សំណើរបស់សហព្រះរាជអាជ្ញាសុំបំពេញកិច្ចស៊ើបសួរបន្ថែមទាក់ទងទៅនឹងខ្មែរកម្ពុជាក្រោម និងការសំលាប់ដ៏ឃោរឃៅនៅក្នុងស្រុកបាកាន ខេត្តពោធិសាត់ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៩ ឯកសារលេខ D274 កថាខ័ណ្ឌ ១។

[30] ដីការួមបញ្ចូល កថាខ័ណ្ឌទី ៣។

[31] D250/3/3 កថាខ័ណ្ឌទី ៧។

បែបនេះ[32]។ មាត្រា ៣.២ (ជ) បានចែងជាទូទៅថា គ្រប់ឯកសារទាំងអស់គួរតែមាន "ចំណងជើងសង្ខេបនៃឯកសារទាំងនោះ ដែលខ្លីតាមតែអាចធ្វើទៅបាន"[33]។ ទាំងមាត្រា៣.២(ជ) ទាំងវិធាននីតិវិធីផ្សេងទៀតមិនបានលើកឡើងទេថា ចំណងជើងនៃលិខិតគឺចាំបាច់តាម ការកំណត់របស់ ក.ស.ច.ស អំពីចរិតលក្ខណៈនៃឯកសារទេ ។ ប្រសិនបើ ក.ស.ច.ស បានពិនិត្យមើលនូវខ្លឹមសារនៃសំណើសុំរបស់សហព្រះរាជអាជ្ញាជាជាងទៅលើទម្រង់សុទ្ធសាធនៃក្បាលទំព័រនៃឯកសារនីមួយៗនោះ ក.ស.ច.ស នឹងបានដឹងថា សំណើទាំងនោះមានបញ្ចូលនូវដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមដែលគួរត្រូវបានស៊ើបអង្កេត។

១១. ជាការពិតណាស់ សំណើរបស់សហព្រះរាជអជ្ញា បានបំពេញដល់សេចក្ដីត្រូវការជាសារធាតុនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមក្រោមវិធាន៥៣ (១) និងមាត្រា ៤.១ នៃសេចក្ដីណែនាំអនុវត្ត។ នៅក្នុងដីកាសម្រេចរួមរបស់ខ្លួន ក.ស.ច.ស បានកត់សំគាល់ថា វិធាន ៥៣ (១) ដែលមានចែងអំពីដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរគឺត្រូវបានអនុវត្តផងដែរចំពោះដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម[34]។ តាមរយៈវិធាននេះ រាល់ឯកសារនីមួយៗត្រូវតែដាក់បញ្ចូល "សេចក្ដីសង្ខេបនៃអង្គហេតុ" "ប្រភេទនៃបទល្មើសដែលត្រូវបានចោទប្រកាន់" "បទប្បញ្ញត្តិច្បាប់ដែលពាក់ព័ន្ធហើយដែលបានកំណត់ និងផ្ដន្ទាទោសចំពោះឧក្រិដ្ឋកម្ម" "ឈ្មោះនៃបុគ្គលដែលត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការស៊ើបអង្កេត ប្រសិនបើអាចធ្វើទៅបាន" និង "កាលបរិច្ឆេទ និងហត្ថលេខារបស់សហព្រះរាជអាជ្ញា"[35]។ លើសពីនេះទៅទៀត សំណើរបស់សហព្រះរាជអាជ្ញាបានបំពេញទៅដល់លក្ខណៈវិនិច្ឆ័យដែលកំណត់ដោយមាត្រា ៤.១ នៃសេចក្ដីណែនាំអនុ

[32] D250/3/3 កថាខ័ណ្ឌទី ៦ ។

[33] សេចក្ដីណែនាំអនុវត្ត, អ.វ.ត.ក/០១/២០០៧ កែសម្រួលលើកទី ៤(សេចក្ដីណែនាំអនុវត្តសំរាប់ការដាក់ឯកសារ) មាត្រា ៣.២ (ជ)។

[34] ដីការួមបញ្ចូល កថាខ័ណ្ឌទី ៦។

[35] វិធាន ៥៣ (១) នៃវិធានផ្ទៃក្នុង។

វត្ថុសំរាប់ការដាក់ឯកសារ ដែលចែងអំពីធាតុផ្សំដែលថា គ្រប់ឯកសារទាំងអស់ដែលត្រូវដាក់ជូនទៅ ក.ស.ច.ស ឬអង្គជំនុំជម្រះត្រូវតែរួមបញ្ចូល[36]។ តាមរយៈមាត្រា ៤.១ គ្រប់ឯកសារដែលត្រូវបានដាក់ជូន ក.ស.ច.ស ឬអង្គជំនុំជម្រះ ត្រូវតែដាក់នូវចំនុចទាំងឡាយតាមការសមស្របដូចជា " សេចក្តីផ្តើមដែលរួមមាន មូលដ្ឋានច្បាប់ និងបណ្តឹងសុំទាមទារអ្វីមួយ" "សេចក្តីសង្ខេបមូលដ្ឋាននៃទឡ្ហីករណ៍" "ការគុសបញ្ជាក់នូវអង្គហេតុដែលជាប់ទាក់ទងនឹងកាលប្រវត្តិដែលសមស្រប" "សេចក្តីសង្ខេបរបស់ច្បាប់ដែលពាក់ព័ន្ធ រាប់បញ្ចូលទាំងការដកស្រង់ប្រភពច្បាប់ដែលទាក់ទង" និង "ទឡ្ហីករណ៍លំអិតផ្នែកច្បាប់"[37]។ សំណើរបស់សហព្រះរាជអាជ្ញាបានដាក់បញ្ចូលនូវគ្រប់លក្ខខណ្ឌទាំងអស់ និងប្រតិបត្តិយ៉ាងមានប្រសិទ្ធភាពដោយឡែកៗ និង/ឬជារួម ក្នុងលក្ខណៈជាដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។

## គ. ក.ស.ច.ស អាចបើកកិច្ចស៊ើបសួរបន្ថែមអនុលោមតាមសំណើរបស់សហមេធាវីដែលមានដោយឡែក និងឯករាជពីសំណើរបស់សហព្រះរាជអាជ្ញា

១២. ទោះជាយ៉ាងណាក៏ដោយ ក.ស.ច.ស បានភាន់ច្រឡំដែលថា ការបដិសេធចំពោះសំណើរបស់សហព្រះរាជអាជ្ញាគឺតម្រូវឲ្យបដិសេធសំណើរបស់សហមេធាវីផងដែរនោះ[38]។ ដូច្នេះ ការភាន់ច្រឡំនេះកើតចេញពីការយល់ច្រឡំចំពោះគោលបំណងរបស់វិធាន ៥៥ ទាក់ទងទៅនឹងកិច្ចស៊ើបអង្កេត ទាំងកិច្ចស៊ើបអង្កេតតាមផ្លូវតុលាការ និងកិច្ចស៊ើបអង្កេតចោទប្រកាន់។

១៣. ដោយមិនគិតអំពីសំណើរបស់សហព្រះរាជអាជ្ញា សំណើរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើឲ្យឃើញនូវឧក្រិដ្ឋកម្មជាច្រើនស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក ដែល ក.ស.ច.ស មានកាតព្វកិច្ចត្រូវបើកកិច្ចស៊ើបសួរអនុលោមតាមវិធាន ២៣(១)(ក)

[36] សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ មាត្រា ៤.១។

[37] Id

[38] សូមមើលឯកសារលេខ D250/3/3 កថាខ័ណ្ឌទី ៩ ។

និងវិធាន ៥៥(១)។ វិធាន ២៣(១)(ក)បានចែងអំពីគោលបំណងនៃការអនុញ្ញាតឱ្យមានការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងដំណើរការនីតិវិធីរបស់ អ.វ.ត.ក គឺដើម្បីអនុញ្ញាតឱ្យជនរងគ្រោះជារូបវន្តបុគ្គលទាំងអស់នោះអាចចូលរួមនៅក្នុងនីតិវិធីព្រហ្មទណ្ឌប្រឆាំងនឹងអ្នកទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក[39]។ ឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នៅក្នុងសំណើសុំបំពេញកិច្ចស៊ើបសួរគឺស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក[40]។ វិធាន ៥៥ (១) ចែងថា កិច្ចស៊ើបអង្កេតត្រូវធ្វើឡើងដោយខានមិនបានចំពោះឧក្រិដ្ឋកម្មទាំងឡាយ ដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក[41]។ ដូចនេះ អ.ស.ច.ស ត្រូវបានតម្រូវឱ្យធ្វើការពិចារណាចំពោះឧក្រិដ្ឋកម្ម និងអង្គហេតុដែលត្រូវបានស្នើឡើងដោយសហមេធាវី នៅក្នុងបរិបថដែលបញ្ហាទាំងអស់នោះត្រូវបានលើកឡើង ពោលគឺដូចបានបង្ហាញឱ្យឃើញនូវគំរូមួយក្នុងរឿងក្តីនៃអំពីប្រល័យពូជសាសន៍ ហើយដែលបានធ្វើការស៊ើបអង្កេតទៅលើឧក្រិដ្ឋកម្មទាំងនោះ ហើយដែលស្ថិតនៅក្នុងយុត្តាធិការ ព្រមទាំងបញ្ជូនបញ្ហាទាំងនេះទៅសហព្រះរាជអាជ្ញាដើម្បីចាត់ការបន្ត ឬមួយក៏ត្រូវពន្យល់ថាតើហេតុអ្វីបានជាកិច្ចស៊ើបអង្កេតដែលត្រូវបានស្នើឡើងនេះ មិនមានភាពចាំបាច់ត្រូវចាត់ការ (វិធាន៥៥(១០))ដែលធ្វើឱ្យ ក.ស.ច.ស សម្រេចបដិសេធនូវសំណើសុំបើកកិច្ចស៊ើបសួរនេះ។ ក.ស.ច.ស ខកខានដោយមិនបានពន្យល់អំពីចំនុចខាងលើនេះ។

១៤. ក.ស.ច.ស យល់ខុសចំពោះវិធាន៥៥ ដោយគាត់បានលើកឡើងថា គាត់មិនមានអំណាចណាមួយដែលផ្តល់ដោយវិធាន ៥៥(២) និង(៣) ឱ្យធ្វើកិច្ចស៊ើបអង្កេតនូវអង្គហេតុដែលស្នើឡើងដោយសហមេធាវីនោះទេ។ វិធាន ៥៥(២)និង(៣)មិនបានលើកឡើងអំពីដើមបណ្តឹងរដ្ឋប្បវេណី និងជនត្រូវចោទនោះទេ ពីព្រោះទាំងដើមបណ្តឹងរដ្ឋប្ប

[39] វិធាន ២៣(១)(ក) (បញ្ជាក់បន្ថែម)។

[40] សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខ័ណ្ឌទី ៧៦។

[41] វិធាន ៥៥ (១)។

វេណី ទាំងជនត្រូវចោទមិនអាចបើកកិច្ចស៊ើបសួរដូចមាននៅក្នុងខ្លឹមសារនៃវិធានផ្ទៃក្នុងនោះឡើយ ប៉ុន្តែអាចត្រឹមតែស្នើសុំឱ្យមានការស៊ើបសួរបន្ថែមប៉ុណ្ណោះ។ ដូច្នេះ វិធាន ៥៥(២)និង(៣) គ្រប់គ្រងទំនាក់នៃកិច្ចស៊ើបអង្កេតចំពោះតែសហព្រះរាជអាជ្ញា និង សហចៅក្រមស៊ើបអង្កេតតែប៉ុណ្ណោះ។ វិធាននេះមិនបានកំរិតការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី មិនបានដកសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំពោះសំណើសុំបំពេញកិច្ចស៊ើបសួរដោយឯករាជ្យ និងមិនបានធ្វើឱ្យប៉ះពាល់ដល់អន្ទានុសិទ្ធិរបស់ ក.ស.ច.ស ក្នុងការទទួលដឹងនូវអង្គហេតុថ្មីលើកឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី ឬក៏ទទួលបានដោយឯកឯង ហើយទទួលធ្វើនូវកិច្ចស៊ើបសួរបន្ថែមដែលមានភាពចាំបាច់សំរាប់ការបើកកិច្ចស៊ើបសួរដូចមានចែងនៅក្នុងវិធាន ៥៥(១០) តាមរយៈមធ្យោបាយនៃអំណាចក្នុងការស៊ើបសួរ ដូចមានចែងនៅក្នុងវិធាន ៥៥(៥)(៨),(៩)។

១៥. តាមការបកស្រាយដ៏សមស្រប វិធាន៥៥ (២)និង(៣)បានលើកថា ក.ស.ច.ស ត្រូវបានសន្មតក្នុងការទទួលស៊ើបអង្កេតនីត្យានុកូលទៅលើអង្គហេតុជាប់ពាក់ពន្ធ័ទាំងឡាយណាដែលបានបង្ហាញនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមដែលសហព្រះរាជអាជ្ញាបានដាក់ជូនរួចមកហើយនោះ[42] ។លើសពីនេះទៅទៀត ចំពោះអង្គហេតុថ្មីដែល ក.ស.ច.ស ទទួលបាន ត្រូវជូនពត៌មានទៅសហព្រះរាជអាជ្ញាដើម្បីបើកការស៊ើបសួរចោទប្រកាន់ ឈានទៅរកការចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ស្នើទៅ ក.ស.ច.ស បំពេញកិច្ចស៊ើបសួរបន្ថែមទៀត[43]។ "កាលណាអង្គហេតុថ្មីនេះ ត្រូវបានបញ្ជូនទៅឱ្យ (ក.ស.ព) នោះ(ស.ច.ស) គ្មានអំណាចធ្វើការស៊ើបសួរអំពីអង្គហេតុថ្មីនោះបានឡើយ លុះត្រាតែទទួលបានដីកា

---

[42] វិធាន ៥៥(២) ( សហចៅក្រមស៊ើបអង្កេតត្រូវធ្វើការស៊ើបសួរតែអង្គហេតុណាដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។)

[43] វិធាន ៥៥(៣) (ក្នុងកំឡុងពេលនៃកិច្ចស៊ើបសួរ ប្រសិនបើមានលេចចេញនូវអង្គហេតុថ្មី ក.ស.ច.ស ត្រូវជូនពត៌មានទៅដល់សហព្រះរាជអាជ្ញា លើកលែងតែអង្គហេតុថ្មីនោះ ជាស្ថានទម្ងន់ទោសនៃអង្គហេតុដែលមានកំណត់នៅក្នុងដីកាសន្និដ្ឋានដែលមានស្រាប់។

សន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពីសហព្រះរាជអាជ្ញា"[44]។ នៅក្នុងបណ្ដឹងឧទ្ធរណ៍បច្ចុប្បន្ន ក.ស.ច.ស មិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួនក្រោមវិធានផ្ទៃក្នុង ៥៥ (៣) ក្នុងការបញ្ជូន "អង្គហេតុថ្មី" ខាងក្រោមដែលទាក់ទងទៅនឹងដើមបណ្ដឹងរដ្ឋប្បវេណី និង/ឬ អ្នកដែលដាក់ពាក្យជាដើមបណ្ដឹងរដ្ឋប្បវេណី និងឬ ក្រុមជនជាតិភាគតិចខ្មែរកម្ពុជាក្រោមជារួមទៅ ក.ស.ព ដើម្បីដាក់បញ្ចូលនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទេ។

ក. ទម្រង់ពត៌មានជនរងគ្រោះ ផែនទី និងសេចក្ដីបញ្ជាក់ដែលបានចុះហត្ថលេខាចេញមកពីដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលមានពត៌មានលំអិតដែលទាក់ទងនឹងឧក្រិដ្ឋកម្មដែលពួកគេទទួលរង ដូចដែលបានស្នើឡើងនៅក្នុងមាត្រា ៣.៥ នៃសេចក្ដីណែនាំអនុវត្តរបស់ អ.រ.គ.ក ស្ដីពីការចូលរួមរបស់ជនរងគ្រោះ[45]។

ខ. របាយការណ៍ចុះស៊ើបអង្កេតដែលមាន ១០៩ ទំព័រ ដែលធ្វើដោយសមាគមការពារសិទ្ធិមនុស្សខ្មែរកម្ពុជាក្រោម (ស.ក.ខ.ក.ក) និង Access to Justice Asia (AJA) ក្នុងខេត្តពោធិ៍សាត់ ខេត្តតាកែវ និងខេត្តកំពង់ឆ្នាំងតាមរយៈកិច្ចសម្ភាសន៍ និងការស្រាវជ្រាវបែបជាតិពន្ធុជាមួយអ្នករស់រានមានជីវិតខ្មែរក្រោម និងវៀតណាមរស់នៅក្នុងខេត្តទាំងនោះ ក្នុងគោលបំណង ជួយ ស.ច.ស ឱ្យបន្ត និងបន្ថែមការស៊ើបអង្កេត[46]។

---

[44] វិធាន ៥៥ (៣)។

[45] លិខិតរបស់ Mahdev Mohan ដាក់ជូនអង្គភាពជនរងគ្រោះ មានចំនងជើងថា ការដាក់ពាក្យទំរង់ពត៌មានជនរងគ្រោះរបស់ខ្មែរក្រោមនៅខេត្តពោធិ៍ និងតាកែវដាក់ជូនទៅអង្គភាពជនរងគ្រោះ ថ្ងៃទី២៣ តុលា ២០០៩ និងដាក់ទៅ ក.ស.ច.ស ដោយអង្គភាពជនរងគ្រោះ ថ្ងៃទី១៣ មករា ២០១០។

[46] ទិន្នន័យស្ដាប់-មើលឃើញ និងរបាយការណ៍ស៊ើបអង្កេតរបស់ AJA/ ស.ក.ខ.ក.ក ទាក់ទងទៅនឹងអ្នករស់រានមានជីវិតនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលបានដាក់ ទៅអង្គភាពជនរងគ្រោះកាលពីថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ២០០៩ ហើយអង្គភាពបានបញ្ជូនទៅ ក.ស.ច.ស កាលពីថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១០។

គ. ស៊ីឌីទិន្នន័យចំនួនពីរមានរូបថត និងការថតវីដេអូ ដែលជាប់ទាក់ទងទៅនឹងឧក្រិដ្ឋកម្មធំៗ និងទីកន្លែងរណ្ដៅសាកសពនៅក្នុងស្រុកបាកាន ខេត្តពោធិ៍សាត់ និងស្រុកគីរីវង់ ខេត្តតាកែវ "ក្នុងគោលបំណងជួយ ស.ច.ស ឱ្យ បន្ត និងបន្ថែមការស៊ើបអង្កេត"[47] ។

ឃ. សំណើរបស់សហមេធាវីមានប្រភពមកពីបឋមសិក្សា និងអនុវិទ្យាល័យចំនួន ៥៥ ទាក់ទងទៅនឹងរឿងក្ដីដែលធ្វើឡើងដោយដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យជាដើមបណ្ដឹងរដ្ឋប្បវេណី។

ង. "អង្គហេតុថ្មី" បានជួបប្រទះនៅក្នុងដំណើរការនៃកិច្ចសម្ភាសន៍ជាមួយប្រជាជនខ្មែរក្រោម ដែល ក.ស. ច.ស យល់ព្រម[48] ។ នៅក្នុងកិច្ចសម្ភាសន៍ជាមួយប្រជាជនទាំងនេះ ក.ស.ច.ស ដឹងអំពីភាពពាក់ព័ន្ធនៃករណីខ្មែរ ក្រោមក្នុងការកំណត់ធាតុផ្សំយុត្តាធិការ និងទម្រង់អនុវត្តដ៏មានសក្ដានុពលនៃការទទួលខុសត្រូវ ប៉ុន្តែ ក.ស.ច.ស មិនបានពិចារណាឱ្យបានត្រឹមត្រូវនូវភស្តុតាងចំពោះឧក្រិដ្ឋកម្មដ៏ធំធេងដែលបានប្រព្រឹត្តប្រឆាំងនឹងខ្មែរក្រោម ថាជាក្រុមមួយនោះទេ និងបានបដិសេធការស៊ើបអង្កេតដោយផ្អែកលើមូលដ្ឋានទាំងនេះ[49]។

១៦. ដោយហេតុថា ក.ស.ច.ស មិនបានបញ្ជូន "អង្គហេតុថ្មី" ទាំងនេះទៅ ក.ស.ព សំរាប់ការស៊ើបអង្កេត នោះទេ ក.ស.ច.ស មិនតំរូវឱ្យកំណត់ការស៊ើបអង្កេតតាមផ្លូវច្បាប់ក្រោមវិធានផ្ទៃ ក្នុង ៥៥ (៣) មកត្រឹមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពី ក.ស.ព នោះទេ។ ទោះជាយ៉ាងណា ដីការួមបញ្ចូលរបស់ ក.ស.ច.ស មិន បានពិចារណាសំណើដែលមាន ៥០ទំព័រ របស់សហមេធាវី ដោយបដិសេធសំណើនេះនៅក្នុងវាក្យខ័ណ្ឌទោលដោយគ្មាន "ការកំណត់មូលហេតុចំពោះការបដិសេធនេះទេ"[50]។ ក្រៅពីការ

---

[47] Id

[48] ដីកាសម្រេចរួម កឋាខណ្ឌទី ៩ ។

[49] ដីកាសម្រេចរួម កឋាខណ្ឌទី ១១ ។

[50] វិធាន ៥៥ (១០) ។

និយាយដូច្នេះ ដីកានេះបានលើកឡើង "គួរ ឱ្យកត់សំគាល់នូវបញ្ហាដូចគ្នា នៅក្នុងសំណើរបស់ ក.ស.ព" ហើយដូច្នេះវាមិនចិតនៅក្នុងវិសាលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមនោះទេ"[51] ។ ក.ស.ច.ស បានណែនាំខុស ដោយខ្លួនឯងនូវវិសាលភាពនៃឆន្ទានុសិទ្ធិផ្ទាល់របស់ខ្លួន ក្រោមវិធានផ្ទៃក្នុង ៥៥ ដោយមិនបានយោង "អង្គហេតុ" ទៅ ក.ស.ព ទេ។ ការណែនាំខុសនេះ មិនត្រឹមតែកំណត់ព្រំដែនមិនចាំបាច់នេះទេ វាថែមទាំងបានបំពានវិធានផ្ទៃ ក្នុង ២១ (១) (គ) ដែលតំរូវថា ឱ្យមានការជូនដំណឹងដល់ជនរងគ្រោះ និងថាសិទ្ធិទាំងនោះត្រូវគេគោរពពេញ មួយនីតិវិធី"[52] ។

១៧. ការកំណត់ជាកណ្ដាលរបស់ ក.ស.ច.ស នៃវិសាលភាពនៃការស៊ើបអង្កេតត្រូវគេកំរិតដោយវិសាលភាពនៃការស៊ើបអង្កេតរបស់ព្រះរាជអាជ្ញា ដូចមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម បានប៉ះពាល់សិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យជាដើមបណ្ដឹងរដ្ឋប្បវេណី។ ចំណាងជើងសារណារបស់ ក.ស.ព ជា "សំណើស៊ើបអង្កេត" មិនមែនជា "សារណាបន្ថែម" នោះទេ គឺជាការខុសប្លែកនៃទម្រង់ ហើយមិនគួរត្រូវគេអនុញ្ញាតឱ្យដកចេញដើមបណ្ដឹងរដ្ឋប្បវេណី ឬបើមិនដូច្នេះទេ បានធ្វើឱ្យបាត់បង់សិទ្ធិរបស់ពួកគេ។ ក.ស.ច.ស អាចជៀសវៀងដោយងាយនូវសេចក្ដីលំអៀងបែបនេះដោយការចង្អុលបង្ហាញឱ្យ ក.ស.ព ឱ្យពិចារណាឡើងវិញនូវវិសោធនកម្មទំព័រមុខនៃសំណើរបស់ពួកគេ និងដាក់ពួកគេនៅក្នុងដីកាសន្និដ្ឋាន បញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។ ក.ស.ច.ស មិនបានសម្រេចជ្រើសរើសធ្វើដូច្នេះទេ និងបានទុកដើម បណ្ដឹងរដ្ឋប្បវេណី អ្នកដាក់ពាក្យជាដើមបណ្ដឹងរដ្ឋប្បវេណី និងសាធារណៈជន (អន្តរជាតិ) ដើម្បីស្ទង់ មើលថាតើហេតុអ្វីបានជា ក.ស.ព បាន

---

[51] ដីកាសម្រេចរួម កឋាខណ្ឌទី ៩ ។

[52] វិធាន ២១ (១) ។

ជ្រើសរើសដាក់សំណើស៊ើបអង្កេត និងមិនមែនវិធានផ្ទៃក្នុង[53]។ ជាការពិតណាស់ បញ្ហាសំខាន់ដូច ករណីខ្មែរក្រោមចំពោះអំពើប្រល័យពូជសាសន៍ និងការធ្វើទុក្ខបុកម្នេញប្រឆាំងនឹងជនត្រូវចោទមិនគួរត្រូវគេទុក ឱ្យមានការរិះគន់នូវការបង្ហាញភាពត្រឹមត្រូវតាមច្បាប់បែបនេះទេ ក្រែងលោជនរងគ្រោះ និងសហគមន៍អន្តរជាតិ បាត់បង់ជំនឿទុកចិត្តនៅក្នុងនីតិវិធីរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងចាត់ទុកថាជាបទពិសោធន៍បរាជ័យមួយ។

១៨. សំរាប់ ក.ស.ច.ស ករណីដែលថាវាគ្មានជម្រើសផ្សេង ប៉ុន្តែបានឈានទៅរកការសន្និដ្ឋានដែលខ្លួនបានធ្វើគឺមិនបានការពារទុកនោះទេ។ ប្រសិនបើ ក.ស.ច.ស មានមន្ទិលសង្ស័យណាមួយអំពីថាតើគេគួរតែដោះស្រាយសំណើរបស់សហមេធាវីដូចម្តេចក្នុងនាមដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យជាដើមបណ្តឹងរដ្ឋប្បវេណី គេគួរស្វះស្វែងរកការបកស្រាយវិធានផ្ទៃក្នុងដែលពាក់ព័ន្ធតាមរបៀបដែលស្របគ្នាជាមួយបទដ្ឋានសិទ្ធិមនុស្ស។ សេចក្តីថ្លែងការណ៍ឆ្នាំ ១៩៨៥ នៃគោលការណ៍ជាមូលដ្ឋាននៃយុត្តិធម៌សំរាប់ជនរងគ្រោះពីឧក្រិដ្ឋកម្ម និងការរំលោភអំណាច ( សេចក្តីថ្លែងការណ៍របស់ជនរងគ្រោះឆ្នាំ១៩៨៥ ) ចែងថា ទស្សនៈ និងក្តីបារម្ភទាំងឡាយរបស់ជនរង គ្រោះ....ត្រូវបានគេបង្ហាញ និងពិចារណានៅគ្រប់ដំណាក់កាលដ៏សមស្របនៃនីតិវិធី ដែលនៅទីនោះផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ពួកគេត្រូវបានទទួលរងផលប៉ះពាល់[54]។

១៩. ជាងនេះទៅទៀត ក.ស.ច.ស មិនបានពិចារណាអ្វីដែលធ្លាប់មានពីមុន នៅក្នុងសាលាក្តីអន្តរជាតិដ៏ទៃទៀត ដូចជាសេចក្តីសម្រេចរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិរ៉្វាន់ដា អង្គជំនុំជម្រះនៅក្នុងរឿងក្តីMuhimana ផ្តល់ការអនុញ្ញាតការចោទប្រកាន់ឱ្យដាក់បញ្ចូលតាមរ

[53] *See Julia Vallace* KR Tribunal Judges Will Not Pursue K Krom Genocide Charges, Cambodia Daily, 20 January 2010. When asked about the OCP's technical decision to label their submissions as investigative requests, ECCC legal affairs spokesperson Lars Olsen made the following statement: "I would assume the co-prosecutors know well the difference between a supplementary submission and a request for investigative action. It was not a mistake. There was a reason why they didn't do it. I know that reason, but I can't tell you".

[54] [54] *Declaration of Basic Principles of Justice for Victims of Crime and Abuse of Power*, Adopted by U.N. General Assembly resolution 40/34, 29 November 1985, principle 6(a).

បៀបនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលគេបានធ្វើវិសោធនកម្មអំពីការចោទប្រកាន់ការរំលោភផ្លូវភេទគឺ មិនត្រូវបានសង្កេតដោយយកចិត្តទុកដាក់នោះទេ។ ក្នុងការឈានទៅរកការសម្រេច អង្គជំនុំជម្រះបានលើកឡើងថា គេត្រូវពិចារណាភាពស្មុគស្មាញ និងការលំបាកជាទូទៅដែលមានជាប់ជាមួយជាចាំបាច់នៅក្នុងការស៊ើបអង្កេតនៃ "ឧក្រិដ្ឋកម្មសង្គ្រាម" ដែលទាមទារការបត់បែនស្របច្បាប់ដែលសមស្របចំពោះវិសោធនកម្មនេះ[55]។ ក.ស.ច.ស គួរតែពិចារណាការលំបាករួម ជាមួយអង្គហេតុថ្មីដែលបានដាក់ដោយអ្នកដាក់ពាក្យជាដើមបណ្តឹងរដ្ឋប្បវេណី និងដើមបណ្តឹងរដ្ឋប្បវេណី និងបានយល់ព្រមចំពោះសំណើរបស់ ក.ស.ព និងសហមេធាវីឱ្យមានការស៊ើបអង្កេតចំពោះការបត់បែងស្របច្បាប់ដែលអាចទទួលយកបាន។

២០. ដោយទទួលស្គាល់នូវសារៈសំខាន់នៃសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការចូលរួមពេញលេញក្នុងនីតិវិធី តុលាការសិទ្ធិមនុស្សអឺរ៉ុបបានគូសបញ្ជាក់ថា ការកំណត់ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវបានគេកំរិត ឬកាត់បន្ថយការទទួលបានរបស់បុគ្គលទៅនឹងនីតិវិធីរបស់តុលាការតាមរបៀបបែបហ្នឹង ឬដល់កំរិតមួយដែលសារៈសំខាន់មែនទែនរបស់សិទ្ធិត្រូវបានគេកាត់បន្ថយ[56]។ អង្គជំនុំជម្រះនេះគឺ យកចិត្តដាក់ចំពោះសារៈសំខាន់នៃសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលគេរំខាន និង ពិចារណា......វាច្បាស់ណាស់ថាដើមបណ្តឹងរដ្ឋប្បវេណី មានសិទ្ធិពេញលេញក្នុងការចូលរួមចាប់ពីដំណាក់កាលស៊ើបអង្កេតរបស់នីតិវិធី ហើយថា ការបញ្ចូលដើមបណ្តឹង រដ្ឋប្បវេណីទៅក្នុងនីតិវិធីគឺជាការទទួលស្គាល់នៃការបន្តនៃដំណើរការផ្សះផ្សាជាតិ[57] អង្គជំនុំជម្រះបានទទួលស្គាល់ផងដែរថាវិធានផ្ទៃក្នុងត្រូវគេរៀបចំឡើង ដើម្បីផ្តល់ឱ្យអង្គបុរេជំនុំជម្រះនូវមធ្យោបាយក្នុងការធានាថាការលំអៀង និងភាពមិនត្រឹមត្រូវពិតប្រាកដណាមួយអាចត្រូវបាន

[55] *The Prosecutor v Mikaeli Muhimana,* ICTR-1995-1B-I, *Decision on Motion tot Amend indictment,* 21 January 2004, para 4.
[56] *Berger* v. *Fr.,* ECHR App. No. 48221/99, 3 December 2002, para. 38.
[57] *Decision on Civil Party Participation in Provisional Detention Appeals,* dated 20 March 2008, C11/53, para. 36-7.

គេដោះស្រាយ[58] បណ្តឹងឧទ្ធរណ៍បច្ចុប្បន្នគឺ ជា ឱកាសផ្តល់ការគោរពដល់គោរពគោលការណ៍ទាំងនេះ។

ឃ- ការកំរិតការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យជាដើមបណ្តឹងរដ្ឋប្បវេណីប៉ះពាល់ ដល់គោលការណ៍ជាមូលដ្ឋានរបស់ អ.វ.ត.ក

២១. ប្រសិនបើគេមិនដាក់បញ្ចូលទៅក្នុងនីតិវិធីនេះ អ្នកដាក់ពាក្យជាដើមបណ្តឹងរដ្ឋប្បវេណីនឹងត្រូវបានគេបដិសេធការចូលរួមនៅក្នុងការកំណត់នៃអង្គហេតុការកំណត់អត្តសញ្ញាណនៃអ្នកទទួលខុសត្រូវ និងការប្រកាសនៃការទទួលខុសត្រូវរបស់ជនដែលដល់ចំពោះឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក។ ផលប្រយោជន៍ទាំងនេះ គឺ ជាចំណុចស្នូលនៃសិទ្ធិដឹងការពិតដែលគេបានបង្កើតឡើងបានយ៉ាងល្អសំរាប់ជនរងគ្រោះនៃការរំលោភសិទ្ធិមនុស្ស[59]។ អ្នកដាក់ពាក្យជាដើមបណ្តឹងរដ្ឋប្បវេណីនឹងត្រូវគេបដិសេធផងដែរក្នុងការចូលរួមនៅក្នុងការកំណត់អត្តសញ្ញាណ ការចោទប្រកាន់ និងការផ្តន្ទាទោសចំពោះអ្នកដែលធ្វើឱ្យរងគ្រោះដល់ពួកគេ ផលប្រយោជន៍ដែលបង្កើតឱ្យមានសិទ្ធិទទួលបានយុត្តិធម៌ដែលគេទទួលស្គាល់ជាលក្ខណៈអន្តរជាតិសំរាប់ជនរងគ្រោះ[60]។ អង្គជំនុំជម្រះនេះបានទទួលស្គាល់ថា ផលប្រយោជន៍របស់ជនរងគ្រោះនៅក្នុងការចូលរួមនៅក្នុងនីតិវិធីមុនកាត់សេចក្តីបណ្តាលមកពីសិទ្ធិស្នូលសំខាន់ពីរៈគឺ សិទ្ធិដឹងការពិត និងសិទ្ធិទទួលបានយុត្តិធម៌ ហើយថាផលប្រយោជន៍ដ៏សំខាន់ទាំងនេះគឺ ទាក់ទងទៅនឹងការអនុវត្តឆន្ទានុសិទ្ធិ[61]។ ដោយសុខចិត្តលះបង់សមភាពសំរាប់ជនរងគ្រោះ ដីការួមបញ្ចូលដក សិទ្ធិដឹងការពិត និងសិទ្ធិទទួលបានយុត្តិធម៌របស់ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យជាដើមបណ្តឹងរដ្ឋប្បវេណី ដោយមិនដាក់បញ្ចូលការរឿងរ៉ាវរបស់ពួកគេជុំវិញអំពើប្រល័យពូជសាសន៍

---

[58] *Decision on Civil Party Participation in Provisional Detention Appeals* at para. 43.
[59] *Prosecutor v. Katanga*, "Decision on the Set of Procedural Rights Attached to the Procedural Status of Victim at the Pre-Trial Stage of the Case," ICC-01/04-01/07-474, 13 May 2008, para. 32.
[60] [60] *Id.* at para. 39.
[61] *Directions on Unrepresented Civil Parties' Right to Address the Pre-Trial Chamber in Person*, dated 29 August 2008, C22/I/69, para. 8.

ដែលពួកគេបានទទួលរងការឈឺចាប់ ដោយសារជនត្រូវចោទ។

២២. ដីការួមបញ្ចូលបំពានផងដែរនូវគោលបំណងដែលបានលើកឡើងរបស់ អ.វ.ត.ក ក្នុងការអនុញ្ញាតឱ្យមានបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណីជាមធ្យោបាយនៃការទទួលស្គាល់សេចក្តីត្រូវការឱ្យមានការផ្សះផ្សាជាតិ។ ក្នុងការបង្កើត អ.វ.ត.ក គោលដៅរបស់អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាគឺត្រូវបន្តឱ្យមានការទទួលខុសត្រូវតាមផ្លូវច្បាប់ដូចជាព្យសនកម្មចំពោះជនរងគ្រោះ និងត្រូវធានាការផ្សះផ្សា និងស្ថេរភាព[62]។

២៣. ដីការួមបញ្ចូលដកយកសិទ្ធិទទួលបានយុត្តិធម៌ និងការចូលរួមរបស់វៀតណាម និងខ្មែរក្រោមនៅក្នុងដំណើរការផ្សះផ្សា និងបន្ថយការយល់ដឹងរបស់ពួកគេ និងស្ថេរភាព។ វាបញ្ជាថា យុត្តិធម៌នៅ អ.វ.ត.ក គឺសំរិតសំរាំង ហើយថាគេអាចប្រព្រឹត្តអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងពួកគេដោយមាននិទណ្ឌភាព ឬដោយគ្មានការ ទទួលស្គាល់គ្រប់គ្រាន់ប្រសិនបើពួកគេមិនបានកើតនៅក្នុងតំបន់ភូមិសាស្ត្រដែលគេចង់បាន។ ការតៀបសង្កត់បែបនេះ គឺមិនល្អនោះទេ ជាពិសេសចាប់តាំងពី អ.វ.ត.ក មានសក្តានុពលក្នុងការធ្វើវិជ្ជមានការចូលរួមចំណែកទៅនឹងដំណើរការផ្សះផ្សាររវាងអ្នករស់រានមានជីវិតខ្មែរក្រោម និងវៀតណាម ជាផលវិបាក (ប្រសិនបើគេមិនផាត់ចេញពីនីតិវិធីនេះ) ជនរងគ្រោះទាំងក្រុមខ្មែរក្រោម និងវៀតណាមនឹងនៅតែមានស្លាកស្នាមដែលមិនអាចជាសះបាននៅក្នុងប្រវត្តិសាស្ត្រ ហើយអ.វ.តកមិនបានបំពេញនូវតួនាទីប្រាប់ការពិតរបស់ខ្លួន ឬតួនាទីខ្លួននៅក្នុងការផ្សះផ្សារជាតិ ។

២៤. ដីកាសម្រេចរួម (Combined order) មិនត្រឹមតែបង្កឧបសគ្គដល់ការផ្សះផ្សារជាតិទេ ថែមទាំងដាក់សំពាធ ដែលដំណើការរបស់ដើមបណ្តឹងរដ្ឋប្បវេណីគឺមានលក្ខណៈសំរិតសំរាំង និងតាមទំនើងចិត្ត ។ ដោយមានអនុត្តរភាពតិចតួចណាស់ចំពោះអ្នកចូលរួមជាជន

---

62 Preamble, Resolution adopted by the General Assembly – the Khmer Rouge Trials, GA Resolution A/RES/57/228, 27, February 2003 ("accountability of individual perpetrators of grave human rights violations is one of the central elements of any effective remedy for victims of human rights violations and a key factor in ensuring a fair and equitable justice system and, ultimately, reconciliation and stability.")

រងគ្រោះ ដែលយ៉ាងក្លាហានក្នុងការប្រាប់រឿងរ៉ាវរបស់ខ្លួន ។ ប្រព័ន្ធច្បាប់ស៊ីវិល ត្រូវបានគេរៀបចំឡើងដើម្បីអនុញ្ញាតិឱ្យជនរងគ្រោះដើរតួនាទីសកម្មនៅក្នុងនីតិវិធីព្រហ្មទណ្ឌ[63]។ វិធាន២៣ (២) បានចែងថា "សិទ្ធិធ្វើបណ្តឹងរដ្ឋប្បវេណី អាចធ្វើឡើងដោយជនរងគ្រោះនៃឧក្រិដ្ឋកម្មដែលស្ថិតក្នុងយុត្តាធិការនៃអង្គជំនុំជម្រះវិសាមញ្ញ (ការគូសបញ្ជាក់បន្ថែម)" ។ ប៉ុន្តែ ដីការួមបញ្ចូល (CO) បានពិនិត្យពិចារណាតែអ្នកដាក់ពាក្យជាដើមបណ្តឹងរដ្ឋប្បវេណីខ្មែរក្រោម តែ៩នាក់ប៉ុណ្ណោះ ។ ដែលអនុញ្ញាតដោយផ្អែកទៅលើការទាក់ទងគ្នាខាងភូមិសាស្ត្រនៃការទាមទាររបស់ពួកគេនៅក្នុងការស៊ើបអង្កេតរបស់តុលាការជាបន្ត ហើយដីកានេះបានបដិសេធអ្នកដាក់បណ្តឹងរដ្ឋប្បវេណីដទៃទៀតទាំងអស់ រួមទាំងអ្នកកំពុងស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីវៀតណាម (CPA VN) ១៦នាក់ (បន្ទាប់ពីដើមបណ្តឹងរដ្ឋប្បវេណី៤នាក់ត្រូវបានគេទទួលស្គាល់ពីមុនថាជាដើមបណ្តឹងរដ្ឋប្បវេណីដោយសហចៅក្រមស៊ើបអង្កេត ហើយថ្មីៗនេះនៅក្នុងខែធ្នូ ឆ្នាំ២០០៩ និងដោយមិនមានគោរពណាមួយដល់គុណសម្បត្តិពិតប្រាកដនៃបណ្តឹងពួកគេ ។ ឧទាហរណ៍ ដូចជាការពិនិត្យពិចារណាចំពោះ(supplementary affidavits ) របស់អ្នកប្តឹងដោយផ្តល់ដោយសហមេធាវី ។ ការធ្វើដូច្នោះ ដីការួមបញ្ចូល បានផ្តល់ឱ្យមានការចូលរួមរបស់ជនរងគ្រោះនៅក្នុងការអនុវត្តដោយខុសច្បាប់ ដែលអនុញ្ញាតឱ្យជនរងគ្រោះមួយចំនួន ចំពោះសិទ្ធិក្នុងការដោះស្រាយនៅពេលបាននូវសំណង (Remedy) ចំខណៈពេលដែលកំពុងមានការទាត់ចោលផ្សេងនូវសិទ្ធិមានយុត្តធម៌ និងឧទាហរណ៍ការទទួលដោយខុសច្បាប់នូវអ្នកដាក់ពាក្យបណ្តឹងជាដើមបណ្តឹងរដ្ឋប្បវេណី និងជាលទ្ធផលបានបដិសេធចោល ដោយមិនមានមូលដ្ឋានច្បាស់លាស់ចំពោះការខុសប្លែកគ្នា ដែលនាំឱ្យលទ្ធផលទី២ ឬមូលដ្ឋាននៃសេចក្តីសម្រេចទី១ ។

២៥. សេចក្តីសម្រេចដែលមានយោបល់ផ្ទុយគ្នារបស់សហចៅក្រមស៊ើបអង្កេតក្នុងកាទទួលការបដិសេធ ឬលើកឡើងវិញពីឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីរបស់អ្នកដាក់ពាក្យប្តឹង

[63] Sarah Thomas និងTerith Chy "ការបញ្ចូលអ្នករស់រានមានជីវិតនៅក្នុងដំណើរការសាលាក្តី" ការជំនុំជម្រះ៖ គណនេយ្យភាពនៃដំណើរការនីតិវិធីខ្មែរក្រហម ។

អាចមានឥទ្ធិពល ឬផលប៉ះពាល់ធំធេងលើពួកគេ រួមជាមួយនឹងអ្វីដែលគេអាចមានអនុភាពបំផ្លាញទៅរូបគាត់វិញ ។ សហមេធាវីកត់សំគាល់នូវការកើនឡើងចំពោះមនោសញ្ចេតនា ក្នុងចំណោមជនរងគ្រោះដែលសិទ្ធិរបស់ពួកគេត្រូវបានកៀសចេញតាមរយៈបទប្បញ្ញត្តិនៃវិធាននិងនីតិវិធីរបស់អ.ត.វ.ក [64]។

២៦. ដីការួមបញ្ចូលដកហូតសិទ្ធិរបស់ជនរងគ្រោះវៀតណាមក្នុងរបបខ្មែរក្រហមអះអាងថាឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តប្រឆាំងពួកគេ ដោយមានផលប៉ះពាល់ដ៏ធំធេងនៃភាពស្ងប់ស្ងាត់នូវសម្លេងរបស់ពួកគេក្នុងបរិបទដែលនៅក្នុងអ្នករស់រានមានជីវិតពីប្រល័យពូជសាសន៍ជនជាតិភាគតិចវៀតណាមតិចតួចណាសនៅក្នុងកម្ពុជា។ វាកាន់តែតិចតួចទៅទៀត ប្រសិនបើមានជនជាតិភាគតិចវៀតណាមក្នុងខេត្តព្រៃវែង ឬស្វាយរៀងបានដាក់ពាក្យតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងចំណែកឯជនជាតិវៀតណាមទាំងក្រុមត្រូវបានគេបដិសេធចំពោះការទទួលរងគ្រោះនៃឧក្រិដ្ឋរបស់គេនៅខេត្តកំពង់ឆ្នាំងនោះ។

២៧. ដីកាសម្រេចរួមបានលុបខ្មែរក្រោមពីកំណត់ត្រាច្បាប់និងប្រវត្តិសាស្ត្ររបស់អវតកដោយបដិសេធ........ការឈឺចាប់របស់ពួកគេជាមួយក្រុម១ ក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ ។ ខ្មែរក្រោមត្រូវបានចាត់ទុករួចទៅហើយថាត្រូវបានគេបំភ្លេចចោល ពួកគេប្រថុយគ្រោះថ្នាក់ដែលមិនគួរឱ្យជឿក្នុងស្វះស្វែងរកការទទួលស្គាល់ចំពោះការរំលោភបំពានដែលទទួលរងនៅក្នុងកណ្តាប់ដៃរបស់ខ្មែរក្រហម ។ ការមិនរាប់បញ្ចូលខ្មែរក្រោមទៅក្នុងនីតិវិធីនឹងធ្វើឱ្យស្ងាត់នូវប្រវត្តិសាស្ត្ររបស់ពួកគេ ហើយជាពិសេសប្រវត្តដំណើររឿងទាក់ទងជាតិរបស់ពួកគេនៅក្នុងរបស់កម្ពុជាប្រជាធិបតេយ្យដ៏យោងខ្លងនោះនឹងមិនត្រូវបានកត់ត្រា ។

---

[64] មើល Guy De Launey អ្នករស់រានមានជីវិតពីខ្មែរក្រហមមានអារម្មណ៍ថាយុត្តធម៌ត្រូវបានបដិសេធ BBC ថ្ងៃ១១ ខែធ្នូ ឆ្នាំ២០០៩ http://news.bbc.co.uk/2/hi/8406427.stm.; មើលផងដែរ ដោយMahdev Mohan, ប្រតិមតិរបស់ក្រុមជនរងគ្រោះ ៖ ការចូលរួមរបស់ជនរងគ្រោះនៅតុលាការខ្មែរក្រហម នៅក្នុងទស្សនាវដ្ដីលេខ៩ (២០០៩) ទំព័រ១ដល់៤៣ របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ។

២៨. ជាងនេះទៅទៀត ខ្មែរក្រោមត្រូវគេផ្តោតទៅលើខ្មែរក្រោមដែលជាក្រុមមួយសម្រាប់សញ្ជាតិវៀតណាម ដែលឧក្រិដ្ឋកម្មប្រព្រឹត្តលើពួកអ្នកទាំងនោះគឺជាអំពើប្រល័យពូជសាសន៍[65]។ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍កាន់កាប់នូវកន្លែងដ៏មានអទីភាពមួយនៅក្នុងចំណោមបទឧក្រិដ្ឋអន្តរជាតិ ។ វាមានសមត្ថភាពតែមួយគត់ក្នុងការទទួលស្គាល់និងការពាំនាំការថ្កោលទោសជាសាកលចំពោះការប្រព្រឹត្តដែលគួរឱ្យរន្ធត់បំផុត គឺវិនាសកម្មចំពោះមនុស្សដោយចេតនា ។ ទំហំ និងលក្ខណៈរបស់មនុស្សទទួលរងការឈឺចាប់ដែលតំណាងដោយអំពើប្រល័យពូជសាសន៍បានរាំងទៅដល់អ្វីដែលគេហៅថា "ឧក្រិដ្ឋដ៏ធំនៅក្នុងទិដ្ឋិភាពសហគមន៍អន្តរជាតិ ក្នុងប្រវត្តិសាស្ត្រ និងនៅក្នុងគំណនៃកូនចៅជំនាន់ក្រោយរបស់ពួកគេ"[66] ។ ការប៉ុនប៉ងរបស់បក្សកុម្មុយនីស្តកម្ពុជា (CPK) ក្នុងការកំទេចខ្មែរក្រោមក្នុងនាមជាប្រជាជនគឺជាឧក្រិដ្ឋកម្មអន្តរជាតិដ៏ធ្ងន់ធ្ងរបំផុត ការហាមប្រាមដែលក្នុងនោះគឺ វិធានអន្តរជាតិដែលមានតម្លៃដាច់ខាត (Jus Cogens) ។ វាពិតជាសំខាន់ខ្លាំងណាស់ចំពោះដើមបណ្តឹងរដ្ឋប្បវេណីនិងអ្នកស្នើតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់កំណត់ត្រាប្រវត្តិសាស្ត្រ កំណត់ត្រាផ្លូវច្បាប់ និងកេរដំណែលអវតក ដែលសហចៅក្រមស៊ើបអង្កេតទទួលស្គាល់ថាឧក្រិដ្ឋកម្មទាំងពីរនេះបានកើតឡើង ទើបធ្វើការស៊ើបអង្កេតការយល់ពីធម្មជាតិ និងវិសាលភាពនៃឧក្រិដ្ឋកម្មទាំងនេះ និងដាក់បញ្ចូលឧក្រិដ្ឋកម្មទាំងនេះនៅក្នុងការចោទប្រកាន់ថ្មីៗប្រឆាំងជនត្រូវចោទ ។

## IV. សេចក្តីសន្និដ្ឋាន និងការស្នើសុំ

ហេតុដូច្នេះហើយ ដូចមានជម្រាបជូននៅក្នុងហេតុផលលើកឡើងខាងលើ សហមេធាវីស្នើសុំអង្គបុរេជំនុំជម្រះសម្រេច៖

[65] Convention on the Prevention and Punishment of the Crime of Genocide, Adopted by the U.N. General Assembly Resolution 260 (III) A of the U.N. General Assembly, 9 December 1948. Entry into force: 12 January 1951.
[66] Diane Marie Amann, Group Mentality, Expressivism, and Genocide, 2 Int'l. Crim. L. Rev. 93, 118 (2002), Annex I

ក- ផ្តល់នូវសវនាការផ្ទាល់មាត់ដើម្បីសម្រេចលើបណ្តឹងឧទ្ធរណ៍នេះ

ខ-ច្រានចោលដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេត

គ-បង្គាប់ឲ្យសហចៅក្រមស៊ើបអង្កេតចាត់នូវកិច្ចស៊ើបអង្កេតចាំបាច់និងបន្ថែមចំពោះខ្មែរក្រោម និងដើមបណ្តឹងរដ្ឋប្បវេណីវៀតណាម និងអ្នកដាក់ពាក្យស្នើតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី យោងតាមវិធាន៥៥(១០) នៃវិធានផ្ទៃក្នុង ដូចតាមសំណើររបស់ហមេធាវី (D250/3) និង

ឃ-បង្គាប់ឲ្យសហចៅក្រមស៊ើបអង្កេត ចោទប្រកាន់ជនត្រូវចោទពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភបំពានធ្ងន់ធ្ងរនៃអនុសញ្ញាទីក្រុងហ្សឺណែវ និងឧក្រិដ្ឋកម្មជាតិ ដោយផ្អែកលើអង្គហេតុនិងភស្តុតាងដែលបានដាក់ជូនដោយដើមបណ្តឹងរដ្ឋប្បវេណីជាខ្មែរក្រោម និងវៀតណាម និងអ្នកដាក់ពាក្យស្នើតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដោយសហមេធាវី និង/ឬសហព្រះរាជអាជ្ញា ។

សូមដាក់ជូនដោយក្តីគោរពដ៏ខ្ពង់ខ្ពស់បំផុត

| មេធាវី នី ចាន់ឌី | | មេធាវី Mahdev MOHAN |
|---|---|---|
| មេធាវី Silke STUDZINSKY | | មេធាវី Lyma NGUYEN |

ធ្វើនៅថ្ងៃទី ១២ ខែកុម្ភះ ឆ្នាំ២០១០